# មេរៀនទី ៣៧៖ ទេវតាមកសួរសុខទុក្ខលោកអ័ប្រាហាំ

## លោកុប្បត្តិ ១៨៖១-១៩៖២៩

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/gZHzMatgomw

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/oyBTC8fD3aM

**គោលបំណង៖** ព្រះធ្វើនូវរឿងអស្ចារ្យជាច្រើន។

**ខគម្ពីរចងចាំ៖ ទំនុកតម្កើង** *"ដ្បិតព្រះអម្ចាស់ជាព្រះដ៏ប្រសើរឧត្ដម ព្រះអង្គជាព្រះមហាក្សត្រដ៏ខ្ពង់ខ្ពស់លើសព្រះនានា"*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ
២. លោកតាអាប្រាហាំ https://youtu.be/OAuJ7i82odA
៣. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់https://youtu.be/I-PzUIJ0MVo

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «បញ្ជូនកែវទឹក»

**សម្ភារៈដែលត្រូវការ៖** កែវ និងទឹក




១.ចែកកុមារជាបីក្រុម ហើយឲ្យពួកគេអង្គុយជាជួរ

២. ឲ្យកែវមួយដែលមានទឹកពេញ។ ពួកគេត្រូវព្យាយាមបញ្ជូនកែវនោះទៅកុមារបន្ទាប់ ដែលនៅពីក្រោយ គេដោយប្រើដៃទាំងពីរ។ ពួកគេត្រូវតែព្យាយាមមិនឲ្យខ្ចាយទឹកចេញពីកែវនោះទេ។

៣. ក្រុមណាដែលអាចបញ្ជូនកែវទឹក ហើយនៅសល់ទឹកច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ

៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា វាគឺពិតជាអស្ចារ្យណាស់ដែលគេមិនបានធ្វើឲ្យខ្ចាយទឹក នៅពេលដែលគេបញ្ជូនកែវទឹកនោះ។ ប៉ុន្តែព្រះបានធ្វើនូវរឿងដ៏អស្ចារ្យជាច្រើនសម្រាប់ពួកយើង។

### ៤. ការណែនាំមេរៀន

តើនរណាជាមនុស្សមានឥទ្ធិពលបំផុតដែលអ្នកធ្លាប់ជួប? ហេតុអ្វីបានជាអ្នកគិតថាមនុស្សម្នាក់នោះខ្លាំង? តើគឺដោយព្រោះតែគេអាចលើករបស់ធ្ងន់ៗបាន? ឬក៏ដោយសារពួកគេមានលុយច្រើន? ទោះបីជាមនុស្សមានអំណាចប៉ុណ្ណាក៏ដោយ ប៉ុន្តែអំណាចរបស់ពួកគេនៅតែមានដែនកំណត់ដែរ។ ពួកគេមិនអាចហោះ ឬដកដង្ហើមនៅក្រោមទឹក ឬធ្វើឱ្យរឿងដែលមិនអាចទៅរួចបានឡើយ។ អ្នកដែលមានអំណាចបំផុតក្នុងលោកគឺព្រះ! ថ្ងៃនេះ យើងនឹងរៀនអំពីព្រះដ៏មានអំណាចរបស់យើង ដែលបានធ្វើនូវរឿងដ៏អស្ចារ្យជាច្រើនសម្រាប់បុរសម្នាក់ដែលមានឈ្មោះថាអ័ប្រាហាំ!

### ៥. រឿងនៅក្នុងព្រះគម្ពីរ

អ័ប្រាហាំនិងក្រុមគ្រួសាររបស់គាត់រស់នៅលើវាលរហោស្ថាន ហើយវាជារឿងកម្រណាស់ដែលមានភ្ញៀវណាចូលមកលេងពួកគេនោះ។ ការធ្វើដំណើរឆ្លងកាត់វាលរហោស្ថានមិនមែនជារឿងដែលងាយស្រួល

នោះទេ។ ដូច្នេះហើយទើបពួកគេមានទំនៀមទម្លាប់យកចិត្តទុកដាក់យ៉ាងល្អបំផុត ចំពោះភ្ញៀវ ទាំងឡាយណាដែលចូលមកលេងពួកគេ។

ប្រជាជននៅជំនាន់នោះគេរស់នៅក្នុងត្រសាលធ្វើជាផ្ទះរបស់ពួកគេ។ ថ្ងៃមួយនៅពេលដែលអ័ប្រាហាំកំពុងអង្គុយនៅមាត់ទ្វារត្រសាលរបស់គាត់។ នៅខាងក្រៅគឺពិតជាមានអាកាសធាតុក្តៅខ្លាំងណាស់។ អ័ប្រាហាំ បានឃើញបុរស ៣ នាក់កំពុងឈរក្បែរត្រសាលរបស់គាត់។ គាត់មិនស្គាល់ថាពួកគេជាអ្នកណានោះទេ ប៉ុន្តែនោះគឺជាព្រះជាម្ចាស់ដែលបានមកលេងនឹងគាត់។ តើអ្នកគិតថាជាការអស្ចារ្យដែរឬទេ?

អ័ប្រាហាំប្រញាប់ចេញទៅទទួលរាក់ទាក់បុរសទាំងបីនាក់នោះ។ គាត់ថែមទាំងឱ្យអាហារ និងហៅពួកគេឱ្យមកសម្រាកផងដែរ ហើយពួកគេក៏បានចូលមកស្នាក់នៅក្នុងត្រសាលរបស់អ័ប្រាហាំ។ អ័ប្រាហាំបានទៅប្រាប់សារ៉ាដែលជាប្រពន្ធរបស់គាត់ពីភ្ញៀវទាំងបី ហើយប្រាប់ឱ្យនាងរៀបចំធ្វើម្ហូប សម្រាប់ពួកគេថែមទៀតផង។ សារ៉ាក៏បានរៀបចំដុតនំ ហើយអ័ប្រាហាំបានរៀបចំសាច់សម្រាប់ធ្វើម្ហូប។

នៅពេលដែលម្ហូបអាហារបានរៀបចំរួចរាល់ អ័ប្រាហាំបានលើកយកមកជូនភ្ញៀវរបស់គាត់។ ពេលដែលពួកគេកំពុងញ៉ាំអាហារនោះ គេបានសួរថាសារ៉ានៅឯណា។ អ័ប្រាហាំបានប្រាប់ពួកគេថានាងនៅខាងក្នុងត្រសាល ឯណោះ។ ហើយពួកគេក៏បានប្រាប់អ័ប្រាហាំថា អ័ប្រាហាំ និងសារ៉ានឹងមានកូនប្រុសម្នាក់នៅឆ្នាំក្រោយ។

អស់រយៈពេលជាច្រើនឆ្នាំណាស់មកហើយដែលព្រះបានសន្យាថា នឹងប្រទាននូវកូនប្រុសម្នាក់ដល់អ័ប្រាហាំ និងសារ៉ា។ ហើយឥលូវនេះពួកគេទាំងពីរនាក់មានវ័យកាន់តែចាស់ណាស់ទៅហើយក្នុងការដែលអាចមានកូនបាននោះ។ អ័ប្រាហាំមានអាយុ ៩៩ ឆ្នាំ ហើយ សារ៉ាមានអាយុ ៨៩ ឆ្នាំ។ សម្រាប់មនុស្សគឺវាហាក់ដូចជារឿងដែលមិនអាចទៅរួចទាល់តែសោះ។ ប៉ុន្តែព្រះបានសន្យាថាពួកគេនឹងមានកូននៅឆ្នាំក្រោយនេះ។ តើវាមិនមែនជារឿងដែលអស្ចារ្យទេឬអី?

សារ៉ាកំពុងស្តាប់នូវការសន្ទនារបស់ព្រះនិងអ័ប្រាហាំ។ នៅពេលដែលនាងបានឮថាព្រះបានសន្យាថានឹងឱ្យនាងមានកូនម្នាក់ នាងក៏បានសើច។ ដំណឹងនេះគឺពិតជាអស្ចារ្យណាស់ ដែលនាងមិនអាចជឿថាអាចអាចទៅរួចនោះឡើយ។ ព្រះបានជ្រាបថាសារ៉ាកំពុងលួចសើច ហើយទ្រង់ក៏មានបន្ទូលទៅអ័ប្រាហាំថា "ហេតុអ្វីបានជាសារ៉ាសើចដូច្នេះថា ដែលចាស់ប៉ុណ្ណោះហើយ តើនឹងមានកូនដែរឬ? តើមានការអ្វីដែលព្រះយេហូវ៉ាធ្វើមិនកើតដែរឬអី ដល់វេលាកំណត់ នោះអញនឹងមកឯឯង លុះគ្រប់ខែហើយ សារ៉ានឹងបង្កើតបានកូនប្រុស១"(លោកុប្បត្តិ ១៨៖១៣-១៤)។ ហើយការនោះគឺពិតជាបានកើតឡើងមែន។ នៅឆ្នាំបន្ទាប់សារ៉ាបង្កើតបានកូនប្រុសម្នាក់! ព្រះបានធ្វើការដែលមិនអាចទៅរួចឱ្យកើតឡើងបាន ចំពោះអ័ប្រាហាំ និងសារ៉ា! តើវាមិនមែនជារឿងដ៏អស្ចារ្យទេឬអី?

ធ្វើជាមនុស្ស យើងមិនអាចធ្វើនូវរឿងគ្រប់យ៉ាងបានទេ។ យើងមិនអាចហោះបានទេបើសិនជាគ្មានជំនួយពីគ្រឿងម៉ាស៊ីន។ យើងមិនអាចដកដង្ហើមនៅក្នុងទឹកបានទេបើសិនជាគ្មានបំពង់អុកស៊ីសែន។ ប៉ុន្តែព្រះ គឺខុសពីយើង។ ទ្រង់អាចធ្វើអ្វីក៏បាន និងអាចធ្វើនូវរឿងគ្រប់យ៉ាង។ គ្មានអ្វីដែលព្រះមិនអាចធ្វើទៅរួចបានឡើយ។ មានហេតុផលមួយដែលយើងត្រូវថ្វាយបង្គំព្រះ គឺដោយព្រោះទ្រង់ជាព្រះដែលមានអំណាចហើយអាចធ្វើគ្រប់ការទាំងអស់បាន។ តើព្រះបានធ្វើនូវរឿងអស្ចារ្យអ្វីសម្រាប់ជីវិតរបស់អ្នក?

## ៦. សំនួរពិភាក្សា

១. តើអ្នកណាបានមកលេងនឹងលោកអ័ប្រាហាំ? *(ទេវតាបីអង្គ)*

២. តើពួកគេបានសន្យាអ្វីជាមួយនឹងអ័ប្រាហាំ? *(សារ៉ានឹងមានកូនប្រុសម្នាក់នៅឆ្នាំក្រោយ)*

៣. តើហេតុអ្វីបានការសន្យានេះហាក់ដូចជារឿងដែលមិនអាចទៅរួច? *(អ័ប្រាហាំមានអាយុ ៩៩ ឆ្នាំ ហើយសារ៉ាមានវ័យ ៨៩ ឆ្នាំហើយ)*

៤. ហេតុអ្វីបានជាព្រះអាចធ្វើនូវរឿងដ៏អស្ចារ្យជាច្រើនបាន? *(ទ្រង់ជាព្រះដែលមានអំណាច)*

៥. តើរឿងអស្ចារ្យអ្វីដែលព្រះអាចធ្វើសម្រាប់អ្នក? *(សូមទុកឱ្យកុមារជាអ្នកឆ្លើយ)*

**៧. ល្បែងកំសាន្ត** «ច្រៀងតាមព្យញ្ជនៈ»




១. ចែកកុមារជា៣ក្រុមស្មើគ្នា ហើយអោយគេអង្គុយជាមួយគ្នា

២. រើសតំណាងក្រុមម្នាក់ពីក្រុមនីមួយៗ មកប៉ាវជាមួយគ្នា។ ក្រុមដែលឈ្នះ នឹងរើសចម្រៀងមួយបទមកច្រៀងមួយប្រយោគ។ នៅពេលដែលចម្រៀងនោះឈប់ នោះក្រុមបន្ទាប់ត្រូវជ្រើសរើសបទចម្រៀងណាក៏បាន ដែលចាប់ផ្តើមដោយប្រើព្យញ្ជនៈដែលក្រុមមុនបានបញ្ចប់នោះ។

ឧទាហរណ៍៖ គឺជាការល្អដែលសរសើរព្រះ (ព្រះ {៣} -> ៣) ព្រះអម្ចាស់យើងល្អណាស់។

៣. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា វាគឺពិតជាអស្ចារ្យខ្លាំងណាស់ដែលកុមារអាចស្វែងរកបទចម្រៀងដែលចាប់ផ្តើមដោយប្រើព្យញ្ជនៈ ដែលក្រុមមុនបានបញ្ចប់។ ព្រះរបស់ពួកយើងគឺពិតជាមានព្រះចេស្តាខ្លាំងណាស់ ដែលព្រះទ្រង់អាចធ្វើរឿងដ៏អស្ចារ្យជាច្រើននៅក្នុងជីវិតរស់នៅរបស់យើង!

**៨. ខគម្ពីរចងចាំ**

**ទំនុកតម្កើង ៩៥៖៣** *"ដ្បិតព្រះអម្ចាស់ជាព្រះដ៏ប្រសើរឧត្តម ព្រះអង្គជាព្រះមហាក្សត្រដ៏ខ្ពង់ខ្ពស់លើសព្រះនានា។"*

**៩. ហត្ថកម្ម** «ទេវតាមកលេងនឹងលោកអ័ប្រាហាំ»



សម្ភារៈដែលត្រូវការ៖ សូមបោះពុម្ពក្រដាសហត្ថកម្ម កូល័រ កន្ត្រៃ និងការបិត

១. ចែកក្រដាសហត្ថកម្មឱ្យកុមារម្នាក់មួយសន្លឹក រួចឱ្យពួកគេផាត់ពណ៌។ ផាត់ពណ៌រូបត្រសាលផងដែរ។

២. កាត់រូបត្រសាល និងកាត់បន្ទាត់ចន្លោះកណ្តាល ហើយបិតភ្ជាប់ពីលើរូបសារ៉ា ធ្វើដូច្នេះនៅពេលដែលយើងបើកសន្លឹកដែលកាត់ចន្លោះកណ្តាលនោះ អ្នកនឹងឃើញរូបសារ៉ានៅក្នុងត្រសាល។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវគឺ ជាព្រះដ៏អស្ចារ្យបំផុត។ ដោយទ្រង់បានប្រទានឱ្យយើងនូវជីវិតដ៏អស់កល្បទាំងដែល យើងត្រូវបានស្លាប់នៅក្នុងអំពើបាបទៅវិញទេ! តើអ្នកបានទទួលស្គាល់ការអស្ចារ្យ ដែលបានកើតមានក្នុងជីវិតអ្នកបានក្នុងកម្រិតណាដែរ? សូមក្រលេកមើលការអស្ចារ្យដែលនៅជុំវិញ អ្នកមិនមែនទាល់តែជារឿងធំ ឬក្នុងស្ថានភាពដ៏អស្ចារ្យនោះទេ ប៉ុន្តែសូមមើលទាំងការដែលតូចៗផងដែរ៖ ដែលរួមមានពន្លឺថ្ងៃរះដ៏ស្រស់ស្អាត, ស្នាមញញឹមនៃទារកតូចៗ, ឬក៏មនុស្សដែល បានទទួលនូវការអត់ទោស និងបានទទួលសេចក្តីស្រឡាញ់ជាដើម។ សូមទូលសូមដល់ព្រះ ឱ្យជួយយើងអាច មើលឃើញនូវការអស្ចារ្យដែលទ្រង់ផ្តល់មកជារៀងរាល់ថ្ងៃ ហើយជួយយើងឱ្យមានសេចក្តីជំនឿរឹងមាំ នៅពេលដែលយើងជួបនូវរឿងដែលយើងគិតថាមិនអាចទៅរួច។

# ទេវតាមកលេងនឹងលោកអ័ប្រាហាំ





សម្ភារៈដែលត្រូវការៈ

សូមបោះពុម្ពក្រដាហត្ថកម្ម កូល័រ កន្ត្រៃ និងការបិត

១. ចែកក្រដាសហត្ថកម្មឱ្យកុមារម្នាក់មួយសន្លឹក រូបឱ្យពួកគេផាត់ពណ៌។ ផាត់ពណ៌រូបត្រសាលផងដែរ។

២. កាត់រូបត្រសាល និងកាត់បន្ទាត់ចន្លោះកណ្ដាល ហើយបិតភ្ជាប់ពីលើរូបសារ៉ា ធ្វើដូច្នេះនៅពេល ដែលយើងបើកសន្លឹកដែលកាត់ចន្លោះកណ្ដាលនោះ អ្នកនឹងឃើញរូបសារ៉ានៅក្នុងត្រសាល។



